ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:........០១៥........គ.ម.ក.ប្រ.ក

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា

*****

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩

# ស ម្រេ ច

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅកំណត់ពីការរៀបចំ . និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា ដែលមានតួនាទី និងភារកិច្ចដូចមានចែងក្នុងអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**)។

**ប្រការ ២.-**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៣.-**

នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានការិយាល័យចំណុះចំនួន ០៣ (បី) ដូចខាងក្រោម ÷

១- ការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ

២- ការិយាល័យត្រួតពិនិត្យប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ

៣- ការិយាល័យត្រួតពិនិត្យសេវារក្សាទុកមូលបត្រ

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

អង្គការលេខរបស់នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៤.-**

ការិយាល័យត្រួតពិនិត្យប្រតិបត្តិការទីផ្សារមូលបត្រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ

- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យការអនុវត្តតាមលក្ខខណ្ឌតម្រូវនៃការអនុញ្ញាតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យការអនុវត្តវិធានប្រតិបត្តិការ និងសេចក្តីណែនាំរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរការនៃការអនុវត្តបញ្ជាទិញ-លក់មូលបត្រប្រចាំថ្ងៃ របស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរការបន្សុីថ្លៃមូលបត្រ (Price Matching) ប្រចាំថ្ងៃរបស់ប្រតិបត្តិករទីផ្សារមូលបត្រ
- តាមដាន និងឃ្លាំមើលប្រតិបត្តិការជួញដូរនៅក្នុងទីផ្សារមូលបត្រក្រៅប្រព័ន្ធ (Over-The-Counter-OTC)
- ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំបង្កើតសន្ទស្សន៍មូលបត្រ ក្នុងទីផ្សារមូលបត្រ
- គ្រប់គ្រង និងត្រួតពិនិត្យការផ្សព្វផ្សាយសន្ទស្សន៍មូលបត្រនានា ក្នុងទីផ្សារមូលបត្រ
- ឃ្លាំមើលសកម្មភាពជួញដូរមូលបត្រផ្សេងៗ ដែលអាចពាក់ព័ន្ធនឹងការប្រព្រឹត្តល្មើស ការជួញដូរផ្ទៃក្នុង និងការជួញដូរមិនប្រក្រតីក្នុងទីផ្សារមូលបត្រ
- រៀបចំករណីសង្ស័យប្រព្រឹត្តល្មើសផ្សេងៗ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- ចូលរួមសិក្សា និងរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធ ដើម្បីអភិវឌ្ឍទីផ្សារនិស្សន្ទ ឬទីផ្សារដេរីវេទីវ (Derivative Market)
- សិក្សា និងវិភាគគោលនយោបាយពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មមូលបត្រក្នុងក្របខណ្ឌតំបន់ និងពិភពលោក
- សិក្សា វិភាគ និងធ្វើរបាយការណ៍អំពីការវាយតំលៃស្ថានភាពទីផ្សារមូលបត្ររួមទាំងសន្ទនីយភាព និងទំនោររបស់ទីផ្សារ
- ចងក្រងស្ថិតិ និងគ្រប់គ្រងទិន្នន័យនៃប្រតិបត្តិការជួញដូរមូលបត្រប្រចាំថ្ងៃ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៥.-**

ការិយាល័យត្រួតពិនិត្យប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតដើម្បីធ្វើជាប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ
- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានាដើម្បីកំណត់គុណវុឌ្ឍិ អនុញ្ញាតអោយធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- ពិនិត្យ និងផ្តល់យោបល់លើគុណវឌ្ឍិរបស់បុគ្គលស្នើសុំធ្វើជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យការបញ្ជូន និងការទទួលព័ត៌មាន ដើម្បីធ្វើការផាត់ទាត់ និងដើម្បីធ្វើការទូទាត់
- រៀបចំគោលការណ៍ណែនាំ ដើម្បីពង្រឹងប្រតិបត្តិការរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- ត្រួតពិនិត្យ និងឃ្លាំមើលដំណើរការផាត់ទាត់ និងទូទាត់មូលបត្រ
- ពិនិត្យរបាយការណ៍ប្រតិបត្តិការទូទាត់មូលបត្រ និងទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- សិក្សា និងវិភាគគោលនយោបាយពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មប្រព័ន្ធផាត់-ទាត់និងទូទាត់មូលបត្រ ក្នុងក្របខណ្ឌតំបន់ និងពិភពលោក
- រៀបចំករណីសង្ស័យប្រព្រឹត្តល្មើសអំពីការផាត់ទាត់ និងទូទាត់ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- សិក្សា វិភាគ និងធ្វើរបាយការណ៍អំពីការវាយតំលៃស្ថានភាពនៃប្រតិបត្តិការផាត់ទាត់ និងទូទាត់ក្នុងវិស័យមូលបត្រ
- ចងក្រងស្ថិតិ និងគ្រប់គ្រងទិន្នន័យនៃប្រតិបត្តិការផាត់ទាត់ និងទូទាត់ ប្រចាំថ្ងៃ
- គ្រប់គ្រងទ្រព្យសម្បត្តិ និងរៀបចំបញ្ជីសារពើភណ្ឌរបស់នាយកដ្ឋានដែល **គ.ម.ក.** ប្រគល់ឱ្យ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៦.-**

ការិយាល័យត្រួតពិនិត្យសេវារក្សាទុកមូលបត្រ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្ដល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិកររក្សាទុកមូលបត្រ
- ពិនិត្យ និងផ្ដល់យោបល់លើពាក្យស្នើសុំការអនុញ្ញាតដើម្បីធ្វើជាប្រតិបត្តិកររក្សាទុកមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរការដាក់ផ្ញើ ដក និងផ្ទេរមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរការរក្សាទុកមូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យការចេញវិញ្ញាបនបត្រជារូបវន្តទទួលស្គាល់មូលបត្រ
- ឃ្លាំមើល និងត្រួតពិនិត្យប្រតិបត្តិការនៃការគ្រប់គ្រងបញ្ជីភាគហ៊ុនិក និងបញ្ជីអ្នកកាន់កាប់មូលបត្រផ្សេងទៀត
- ឃ្លាំមើល និងត្រួតពិនិត្យដំណើរនៃការផ្ដល់ការអនុវត្តសិទ្ធិភាគលាភ សិទ្ធិបោះឆ្នោត និងសិទ្ធិផ្សេងទៀតរបស់អ្នកកាន់កាប់មូលបត្រ
- សិក្សា និងវិភាគគោលនយោបាយពាក់ព័ន្ធនឹងការធ្វើសមាហរណកម្មសេវារក្សាទុកមូលបត្រ ក្នុងក្របខណ្ឌតំបន់ និងពិភពលោក
- រៀបចំករណីសង្ស័យប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងការដាក់ផ្ញើ ការដក ការផ្ទេរ និងការរក្សាទុកមូលបត្រ ដើម្បីបញ្ជូនទៅនាយកដ្ឋានកិច្ចការគតិយុត្ត
- សិក្សា វិភាគ និងធ្វើរបាយការណ៍អំពីការវាយតំលៃស្ថានភាពរក្សាទុកមូលបត្រ ការគ្រប់គ្រងបញ្ជីអ្នកកាន់កាប់មូលបត្រ និងការអនុវត្តសិទ្ធិនានា
- ចងក្រងស្ថិតិ និងគ្រប់គ្រងទិន្នន័យនៃប្រតិបត្តិការដាក់ផ្ញើ ដក ផ្ទេរ និងរក្សាទុកមូលបត្រ
- រៀបចំរបាយការណ៍ជាប្រចាំពាក់ព័ន្ធនឹងការអនុវត្តការងាររបស់ការិយាល័យ
- អនុវត្តការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០៩

**គាត ឈន់**

**ចម្លងជូន :**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា និងសមាជិក គ.ម.ក.
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ប្រកាសលេខ ០១៥ ជថក.ប្រ.ក

ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

អង្គការលេខរបស់នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

នៃគណៈកម្មការមូលបត្រកម្ពុជា

